សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ: ១៦០ "ខ"

ចុះថ្ងៃទី ២៤-០១-២០១៨

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៥០៥២

ចុះថ្ងៃទី១២-០៨-២០១៧

## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ វេលាម៉ោង៨ និង៣០ នាទីព្រឹក ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោ[redacted]ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោកស្រី[redacted]ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៥០៥២ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ៖

-ឈ្មោះ[redacted]ភេទប្រុស កើតថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨៨ ជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតផ្ទះលេខ១៩១ ផ្លូវលំ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កំរិតវប្បធម៌និស្សិតឆ្នាំទី២ (អក្សរសាស្ត្រអង់គ្លេស) សាសនាព្រះពុទ្ធ មុខរបររត់ម៉ូតូឌុប ទីលំនៅមុនពេលឃុំខ្លួននៅ ផ្ទះលេខ១៩១ ផ្លូវលំ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted]"ស្លាប់" ម្តាយឈ្មោះ [redacted] "រស់"ប្រពន្ធឈ្មោះ [redacted]"រស់" កូន១ នាក់ ជាទីតិជន ទោសពីមុន គ្មាន ។

-ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៦៥៧៤ "ធ"ដ ឃ ដ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៧ ។

-លោក [redacted]ជាមេធាវីការពារឱ្យសិទ្ធិឲ្យជនជាប់ចោទ មានការិយាល័យផ្ទះលេខ៩០៣B ផ្លូវលេខ៩A សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

-ជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅផ្លូវលំ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង ១៤ រសៀល សមត្ថកិច្ចមន្ត្រីប្រឆាំងគ្រឿងញៀន បានធ្វើការបង្ក្រាបករណី ជួញដូរដោយខុសច្បាប់នូសារធាតុញៀន និង ប្រើប្រាស់ដោយខុសច្បាប់[illegible]



Scanned by CamScanner

ញៀន នៅចំណុចផ្លូវលំ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយមួយ អ្នកទិញថ្នាំញៀនមកសួររកទិញពីឈ្មោះ[redacted]ភេទប្រុស។ ហើយឈ្មោះ [redacted]បានទំនាក់ទំនង ទៅទិញថ្នាំញៀនពីឈ្មោះ [redacted] ភេទប្រុស ដើម្បីយកមកចែកចាយបន្ត ក្រោយពីបានទទួលថ្នាំញៀនហើយ ឈ្មោះ [redacted]បានយកថ្នាំញៀនទៅប្រគល់ឱ្យមួយនៅផ្លូវលំក្នុងភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រ លេខ៦ ខណៈនោះសមត្ថកិច្ចបានឃាត់ខ្លួនជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស ព្រមទាំងវត្ថុតាងមាន ថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ៥កញ្ចប់ទម្ងន់ ១,២១(មួយក្បៀសម្ភៃមួយក្រាម) និងកសាងសំណុំរឿង បញ្ជូនមកតុលាការចាត់ការតាមនីតិវិធីច្បាប់ ។

-បានឃើញ របាយការណ៍សំយោគលេខ ៧០៥/រ.ប.ក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៧ របស់មន្ទីរប្រឆាំងគ្រឿងញៀន ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣១៩៤ អ.យ "ម" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០១៧ របស់ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៤៨២ អ.យ "ម" ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៩៦៩ "គ១" ដ.ដ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង ២ រសៀល ខ្លួនកំពុងនៅផ្ទះជួលនៅផ្សារគីឡូម៉ែត្រលេខ៦ បានទទួលទូរស័ព្ទមកប្រាប់ខ្លួនឱ្យយកថ្នាំញៀនពីគាត់ ដើម្បីទុកឱ្យឈ្មោះ[redacted]ភេទប្រុស អាយុ៣០ ឆ្នាំ ស្នាក់នៅផ្សារគីឡូម៉ែត្រលេខ៦ បន្ទាប់មកខ្លួនបាន ទៅយកថ្នាំញៀនពីឈ្មោះ[redacted]ខាងលើបានចំនួន ៨ កញ្ចប់តូច រួចត្រឡប់មកផ្ទះវិញ ដើម្បីរង់ចាំ ឈ្មោះ[redacted] មកយកថ្នាំញៀនលុះប្រហែលជា ១ ម៉ោងក្រោយមកឈ្មោះ[redacted]បានមកយក ថ្នាំញៀនចំនួន ០៣ កញ្ចប់។ ពេលខ្លួនដើរចេញទៅក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនបានរកឃើញថ្នាំញៀនចំនួន ៥ កញ្ចប់ដែលខ្លួនបានទុកនៅក្នុងហោប៉ៅខោខាងឆ្វេង ។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនរយៈពេលជាង ២ ខែ មកហើយកន្លងមកឈ្មោះ[redacted]បានឱ្យខ្លួនលក់ថ្នាំញៀនឱ្យវារយៈពេល២ ទៅ៣ខែមកហើយដោយ ឱ្យលក់ម្តង១០ កញ្ចប់ហើយឈ្មោះ[redacted]ឱ្យកម្រៃខ្លួន ២០,០០០រៀលទៅ ៣០,០០០ រៀល ។

-តាមរំណាយលទ្ធផលកោសលវិច័យលេខ ១១៦០៨/១៧ ម.ព.អជ.ប.គ.ញ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ បានបញ្ជាក់ថាសំណាកជាគ្រឿងញៀនប្រភេទម្សៅក្រាមឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅម៉ាកទឹកកក ឬអាយ) ដែលមានកម្រិតភាពសុទ្ធ ៧៥,៦១% នៃទម្ងន់សរុបវាស្តិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុង តារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន របស់ឈ្មោះ[redacted]

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ក្រោយពីបានស្តាប់ការសួរដេញដោលរួចមក ឃើញថាមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទទាំងអស់ដូច ការបញ្ជូនសំណុំរឿងមកជំនុំជម្រះ និងសុំតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៤៤៨២ អ.យ.ម ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ២០១៧ ទុកជា



Scanned by CamScanner

ដដែល ។

-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសាកសួរដេញដោលនាពេល និងស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ឃើញថាកូនក្តីខ្លួនឈ្មោះ [redacted] បានសារភាពថាខ្លួនពិតជាបានជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនពិតមែន ។ ការប្រើប្រាស់គ្រឿងញៀនជាជំងឺសង្គមហើយនាំឱ្យបះពាល់សង្គម ដែលនាំឱ្យកូនក្តីរបស់ខ្លួនបានធ្លាក់ខ្លួនចូលទៅក្នុងវិបត្តិគ្រឿងញៀនពីអ្នកប្រើប្រាស់គ្រឿងញៀន រហូតសម្រេចចិត្តធ្វើការរកស៊ីលក់គ្រឿងញៀន។ ដោយផ្អែកតាមមាត្រា ២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានគោលបំណងដើម្បីព្យាបាល ។ ដើម្បីឱ្យកូនក្តីខ្លួនកសាងខ្លួនឆាប់បានត្រឡប់ទៅផ្ទះមើលថែក្មេងតូចអាយុ ២ឆ្នាំ ដែលឪពុករបស់គេបានស្លាប់បាត់ហើយ ។ សូមលោកចៅក្រមមេត្តាសម្រាលទោសដល់កូនក្តីខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] បាននិយាយសម្តីចុងក្រោយថា: សុំឱ្យតុលាការសម្រាលទោស ។

-ក្រោយពីបាន ស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបាន ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ក្រោយពីបាន ស្តាប់ជនជាប់ចោទនិយាយសម្តីចុងក្រោយ ។

-ក្រោយពីបាន ពិនិត្យលើឯកសារភស្តុតាងនានា ។

-ក្រោយពីបាន ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## <u>សាលាដំបូងរាជធានីភ្នំពេញ</u>

## <u>យល់ឃើញថា</u>

១-កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង១៤ រសៀល នៅចំណុច ផ្លូវលំ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កម្លាំងសមត្ថកិច្ចនៃមន្ទីរប្រឆាំងគ្រឿងញៀនបានធ្វើការបង្ក្រាបករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទ ប្រើប្រាស់ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយបានធ្វើការឃាត់ខ្លួនបានជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨៧ ព្រមទាំងចាប់យកវត្ថុតាងគ្រឿងញៀនក្រាមពណ៌សថ្លាចំនួន ៥កញ្ចប់ទម្ងន់ ១,២១ (មួយក្បៀសម្ភៃមួយក្រាម) ពេលដែលជនជាប់ចោទកំពុងលក់គ្រឿងញៀន ។

២-តាមចម្លើយនាពេលសវនាការ និងដំណាក់កាលតំណាងអយ្យការ របស់ជនជាប់ចោទឈ្មោះ [redacted] ពុំទូតែបានឆ្លើយប្រហាក់ប្រហែលគ្នាថា កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង ២ រសៀល ខ្លួនកំពុងនៅផ្ទះជួលនៅផ្សារគីឡូម៉ែត្រលេខ៦ បានទទួលទូរស័ព្ទមកប្រាប់ខ្លួនឱ្យយកថ្នាំញៀនពីគាត់ដើម្បីទុកឱ្យឈ្មោះ [redacted] ភេទប្រុស អាយុ៣០ ឆ្នាំ ស្នាក់នៅផ្សារគីឡូម៉ែត្រលេខ៦ បន្ទាប់មកខ្លួនបានទៅយកថ្នាំញៀនពីឈ្មោះ [redacted] លើបានចំនួន ៨ កញ្ចប់តូច រួចត្រឡប់មកផ្ទះវិញ [illegible] ឈ្មោះ [redacted] មកយកថ្នាំញៀនលុះប្រហែលជា ១ ម៉ោងក្រោយមកឈ្មោះ [redacted] បានមកយកថ្នាំញៀនចំនួន០៣ កញ្ចប់។ ពេលខ្លួនដើរចេញទៅក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនបាន [illegible] ថ្នាំញៀនចំនួន ៥ កញ្ចប់ដែលខ្លួនបានទុកនៅក្នុងហោប៉ៅខោខាងឆ្វេង។ ខ្លួនធ្លាប់ប្រើប្រាស់ថ្នាំញៀនរយៈ [illegible] ហើយកន្លងមកឈ្មោះ [redacted] បានឱ្យខ្លួនលក់ថ្នាំញៀនឱ្យរយៈពេល២ ទៅ៣ ខែ [illegible]



Scanned by CamScanner

លក់ម្តង ១០ កញ្ចប់ហើយឈ្មោ[redacted]ឲ្យកម្រៃខ្លួន ២០,០០០រៀលទៅ ៣០,០០០ រៀល ។

៣-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ[redacted] របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងវត្ថុតាងដែលបានដកហូត អាចបញ្ជាក់ថាជនជាប់ចោទឈ្មោ[redacted]ពិតជាបានធ្វើសកម្មភាពយកគ្រឿងញៀនទៅលក់ដើម្បីយកប្រាក់កម្រៃ ដែលអំពើនេះជាបទល្មើសព្រហ្មទណ្ឌ បទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ហើយជនជាប់ចោទរូបនេះក៏បានសារភាពផងដែរថារូបគេបានប្រើប្រាស់គ្រឿងញៀនផងដែរ ។

៤-វត្ថុតាងចាប់យក ថ្នាំញៀនប្រភេទក្រាមពណ៌សថ្លាចំនួន ០៥កញ្ចប់តូចទម្ងន់ ១.២១(មួយក្បៀសម្ភៃមួយក្រាម) ដែលសមត្ថកិច្ចដកហូតបានពីជនជាប់ចោទឈ្មោ[redacted]ជាភស្តុតាងស៊ីសង្វាក់ដែលអាចឱ្យតុលាការជឿបានថាជនជាប់ចោទឈ្មោះ[redacted]ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

៥-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១១៦០៨/១៧ ម.ព.អជ.ប.គ.៣ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់មន្ទីរពិសោធន៍នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញថាថ្នាំញៀនដែលដកហូតបានពីជនជាប់ចោទឈ្មោ[redacted] ប្រភេទក្រាមម្សៅថ្លា ពណ៌សមានឈ្មោះមេតំហ្វេតាមីន(ហៅក្រៅអាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧៥,៦១% នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ។ ថ្នាំញៀនដែលដកហូតបានពីជនជាប់ចោទឈ្មោះ[redacted]មានទម្ងន់១,២១ ក្រាមមានកម្រិតភាពសុទ្ធចំនួន $\frac{១,២១ g \times ៧៥,៦១}{១០០}$ =០,៩១ ក្រាមដូច្នេះក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នេះត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៦-ជនជាប់ចោទឈ្មោះ[redacted]ក្នុងពេលប្រព្រឹត្តបទល្មើសជននេះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើល្មើសរបស់ខ្លួន ចំពោះមុខច្បាប់ព្រហ្មទណ្ឌជាធរមាន ។

៧-អំពើរបស់ជនជាប់ចោទឈ្មោ[redacted]បានបង្ហាញឱ្យឃើញថាគ្រប់សកម្មភាពមុន និង ក្នុងពេលប្រព្រឹត្តក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើសជនជាប់ចោទរូបនេះមានចេតនាទុច្ចរិតដែលការប្រព្រឹត្តនេះធ្វើឱ្យខូចខាត របៀបរៀបរយសាធារណៈសណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់និរន្តរភាពសង្គម និងបំពានលើមាត្រាដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៨-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted]ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ផ្លូវលំ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៩-ជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស ជាជនក្រីក្រគ្មានកំរិត វប្បធម៌ហើយតាមដំណើររឿងក្តីកន្លង មកជនជាប់ចោទរូបនេះពុំធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសម្តងណាឡើយ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី ។



Scanned by CamScanner

១០-វត្ថុចាប់យកមាន: ក្រោមពណ៌សថ្លាចំនួន៥ កញ្ចប់តូចទម្ងន់សរុប ១,២១(មួយក្បៀសម្ភៃមួយក្រាម) ដែលសល់ពីការធ្វើតេស្តពិសោធន៍បឋមរួចបានវេចខ្ចប់ដោយ មានការទទួលស្គាល់ និងស្នាមម្រាមដៃស្តាំពីជនជាប់ចោទឈ្មោះ [redacted] ត្រូវបានចៅក្រមស៊ើបសួរផ្ញើរសំណាកយកទៅធ្វើកោសលវិច័យទាំងអស់ពុំមាននៅសល់ទេ ដូច្នេះពុំមានវត្ថុតាងថ្នាំញៀននៅសល់ដែលត្រូវឲ្យតុលាការសម្រេចរឹបអូសនោះទេ ។

១១-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបានតម្កល់បទចោទប្រកាន់ និងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅផ្លូវលំ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី ។

១២-សេចក្តីសន្និដ្ឋានរបស់មេធាវីឈ្មោះ [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទសុំឲ្យតុលាការបន្ធូរបន្ថយទោសឲ្យកូនក្តីខ្លួន គប្បីតុលាការពិចារណាក្នុងការសម្រេចសេចក្តី ។

១៣-ជនជាប់ចោទឈ្មោះ [redacted] បានធ្វើសំណូមពរជាសំដីចុងក្រោយថាសុំឲ្យតុលាការសម្រាលទោស គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី ។

<u>**ហេតុដូច្នេះសម្រេច**</u>

១-ផ្តន្ទាទោស ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៨៧ ជាតិខ្មែរ សញ្ជាតិខ្មែរដាក់ពន្ធនាគារកំណត់ ០៣(បីឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៤,០០០,០០០(បួនលានរៀល)បង់ចូលថវិកាជាតិ។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទ ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅផ្លូវលំ ភូមិក្រោលគោ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ កថាខណ្ឌទី៤ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ អង្គារ ៦រោច ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៨

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

-៥-

[redacted]

Scanned by CamScanner